**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~***~~~

សាលាដំបូងខេត្តកណ្តាល

សាលក្រមព្រហ្មទណ្ឌលេខ: **០៦៣(ឧ)**

ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០

## **តាងនាមប្រជារាស្ត្រខ្មែរ**
## **សាលាដំបូងខេត្តកណ្តាល**

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

### **ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

### **តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### **ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

### **មេធាវី**

លោក [redacted] និងលោកស្រី [redacted] មេធាវីការពារក្តីឲ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: **១២៣០ អក** ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] វីរៈ ហៅ **ល័ក្ខ** ភេទប្រុស អាយុ ៣០ឆ្នាំ ជាជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] វេង (រ) ម្តាយឈ្មោះ [redacted] សុខន (រ) ប្រពន្ធឈ្មោះ [redacted] ស្រីមុំ មានកូន ០២ នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (**ក្នុងឃុំថ្ងៃខែឆ្នាំ ១២.០៩.២០១៩**)

ពីបទ: **ឃាតកម្ម** ប្រព្រឹត្តនៅភូមិពោធិ៍ក្រោម ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] **ស្រីមុំ** ភេទស្រី អាយុ ៣៣ឆ្នាំ មុខរបរ កម្មកររោងចក្រ ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ [redacted] ខេត្តកណ្តាល។ (ទទួលមរណភាព)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីណា** ភេទស្រី អាយុ៤៥ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល។ (ជាបងស្រីបង្កើតជនរងគ្រោះ)

### **ដំណើររឿងមានដូចតទៅ**

កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង០៦ល្ងាច មានឈ្មោះ [redacted] វីរៈ និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ បានហូបបាយជុំគ្នាជាធម្មតា លុះដល់ម៉ោងជាង៩យប់ ក៏ឡើងទៅដេកនៅលើបន្ទប់ឡៅតឿជាមួយគ្នាដោយម្នាក់ៗមើលទូរស័ព្ទរៀងៗខ្លួន។ នៅពេលនោះឈ្មោះ [redacted] ស្រីមុំ និយាយសុំលែងលះជាមួយនឹងប្តីឈ្មោះ [redacted] វីរៈ ដោយប្តីមិនគិតទៅធ្វើការរកលុយគិតតែលេងល្បែង ភ្លាមនោះឈ្មោះ [redacted] វីរៈ បាននិយាយថា
~~~

ខ្លួនមិនព្រមលែងលះទេ តែប្រពន្ធនៅតែនិយាយដដែលៗរឿងលែងលះ ដោយខឹងប្រពន្ធនិយាយដដែលៗញឹកញាប់ពេកឈ្មោះ [redacted] វីរៈ ក៏បានយកដៃទាំងពីរច្របាច់កប្រពន្ធ រួចឡើងជិះពីលើធ្វើឲ្យប្រពន្ធរើពុំរួចរហូតដល់ដាច់ខ្យល់ស្លាប់ ។ បន្ទាប់មកឈ្មោះ [redacted] វីរៈ បានប្តូរសំលៀកបំពាក់ឲ្យប្រពន្ធរួចដេកអោបប្រពន្ធ ដោយយំស្តាយស្រណោះ ។ លុះដល់ម៉ោងរំលងអធ្រាត្រ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ[redacted]វីរៈ បានយកភួយគ្របពីលើប្រពន្ធ ហើយយកខោអាវពីក្នុងទូទៅគរលើសាកសពប្រពន្ធ បន្ទាប់មកឈ្មោះ[redacted]វីរៈ បានចុះមកកាត់ទុយយោម៉ូតូបង្ហូរយកសាំងដាក់ដបទឹកសុទ្ធ យកទៅចាក់ដុតនៅក្នុងបន្ទប់ឡៅតឿបណ្តាលឲ្យឆេះចូលទៅក្នុងបន្ទប់ ។ លុះក្រោយមកឈ្មោះ[redacted]វីរៈ បានយកសាំងដែលនៅសល់យកមកចាក់លើខ្លួន ដើម្បីដុតសម្លាប់ខ្លួនតាមប្រពន្ធដែរ ប៉ុន្តែដោយសារមានការឈឺចាប់ទ្រាំមិនបានឈ្មោះ [redacted] វីរៈ ក៏បានយកទឹកចាក់ពន្លត់ភ្លើងដែរឆេះខ្លួន។ បន្ទាប់មកទៀតក៏លោតចុះពីលើផ្ទះទៅលោតទឹក ហើយបានឡើងគោកវិញក៏យកកង់ជិះទៅផ្ទះឪពុករបស់ខ្លួនទើបបានគ្រួសារយកទៅព្យាបាលនៅមន្ទីរពេទ្យ ។ លុះដល់ថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ ២០១៩ ទើបបានសមត្ថកិច្ចឃាត់ខ្លួនកជននោះបញ្ជូនមកតុលាការ ។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខៈ ១១៣៧ ដកសព/១៩ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ១១៧៣ ដក.បជរ/១៩ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

-ដីកាចាត់តាំងប្រធានប្រឹក្សាជំនុំជម្រះបន្តលេខៈ ១២១៩ ដកចត/១៩ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១៩ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

-ក្រោយពីបានស្តាប់សំដីចុងក្រោយជនជាប់ចោទ

## សំអាងហេតុ

១-កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៩ ស្ថិតនៅភូមិពោធិ៍ក្រោម ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ ឃាតកម្ម ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] វីរៈ បានសកម្មភាពយកដៃទាំងពីរច្របាច់កប្រពន្ធ ហើយឡើងជិះពីលើធ្វើឲ្យប្រពន្ធរើពុំរួចរហូតដល់ដាច់ខ្យល់ស្លាប់ ដោយសារជនជាប់ចោទបានខឹងនឹងប្រពន្ធសុំលែងលះ ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វីរៈ បានឆ្លើយនាពេលសវនាការថា៖ មុនកើតហេតុ ប្រពន្ធខ្លួនបានខឹងនឹងខ្លួនមិនទៅធ្វើការ ក៏ខឹងខ្លួននិងសុំខ្លួនលែងលះ ហើយខ្លួនថាមិនលែងទេ ។ លុះដល់ថ្ងៃកើតហេតុប្រពន្ធខ្លួនត្រឡប់មកពីធ្វើការវិញ ក៏នាំគ្នាហូបបាយ ក្រោយពីហូបបាយរួចប្រពន្ធខ្លួនក៏ឡើងសំរាកនៅបន្ទប់ហើយ

ខ្លួនឡើងទៅបន្ទប់ដេ ពេលនោះប្រពន្ធខ្លួននៅតែនិយាយពាក្យថាសុំលែងលះពីខ្លួនដដែល ហើយខ្លួនក៏ លួងកុំឲ្យប្រពន្ធខឹង តែប្រពន្ធខ្លួននៅតែសុំលែងលះ។ ពេលនោះខ្លួនមានអារម្មណ៍ខឹង ហើយនិយាយថាបើ លែងខ្លួនទាល់តែស្លាប់ទាំងពីរនាក់។ ពេលនោះខ្លួនឡើងជិះពីលើប្រពន្ធ យកដៃទាំងពីរច្របាច់កប្រពន្ធខ្លួនរហូតដល់ស្លាប់។ ឃើញថា ចម្លើយនេះអាចឲ្យតុលាការជឿបាន ព្រោះថាចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ។

៣-តាមម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីណា** បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ ក្មួយខ្លួនស្រី ណុចបានតេទូរស័ព្ទប្រាប់ថា ភ្លើងឆេះផ្ទះយាយហើយ ឮដូចនេះក៏ប្រាប់ប្ដីខ្លួន និងកូនប្រសារខ្លួនឲ្យទៅមើល លុះព្រឹកឡើងខ្លួនទៅកន្លែងកើតហេតុមិនបានឃើញអ្វីទេ ឃើញថាមានភ្លើងឆេះផ្ទះម្ដាយខ្លួនមែន ចំណែកសព ប្អូនស្រីខ្លួនឃើញនៅបន្ទប់ឡៅតឿពីចម្ងាយ ចំណែកឯឈ្មោះ [redacted] វីរៈ បានរត់បាត់ហើយ ។ កន្លងមកមុនពេល កើតហេតុប្រហែល ៣ ទៅ៤ ថ្ងៃមុន ប្អូនខ្លួនឈ្មោះ [redacted] ស្រីមុំ បានប្រាប់ថាចង់លែងលះប្ដី ព្រោះថាប្ដីនេះមិន ទៅធ្វើការរកលុយអីទេ គឺគិតតែពីជល់មាន់ ។

៤-តាមចម្លើយសាក្សីឈ្មោះ [redacted] **សុខហឿន** បានបញ្ជាក់ថា៖ មុនថ្ងៃកើតហេតុ ឈ្មោះ [redacted] ស្រីមុំ បាន តេទូរស័ព្ទមកសួរថា មានឃើញឈ្មោះ [redacted] វីរៈ ទៅធ្វើការអត់ ខ្លួនថាឃើញនៅផ្ទះអត់ទៅធ្វើការទេ ។ នៅថ្ងៃ កើតហេតុ ពេលខ្លួនកំពុងតែដេកលក់ ស្រាប់តែឮអ្នកជិតខាងស្រែកថា ភ្លើងឆេះផ្ទះឈ្មោះ [redacted] ស្រីមុំ ហើយ ខ្លួនក៏ស្ទុះងើបឡើងរត់សំដៅទៅផ្ទះនោះ រួចខ្លួនស្រែកថាភ្លើងឆេះផ្ទះហើយ បន្ទាប់មកអ្នកភូមិបាននាំគ្នាយកទឹក ទៅពន្លត់ភ្លើង ក្រោយមកក៏ឃើញឈ្មោះ [redacted] ស្រីមុំ ដេកស្លាប់នៅលើឡៅតឿ ចំណែកឈ្មោះ [redacted] វីរៈ ខ្លួនអត់ ឃើញទេ ។

៥-ទាំងចម្លើយជនជាប់ចោទ , ដើមបណ្ដឹងរដ្ឋប្បវេណី , ចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រី នគរបាលយុត្តិធម៌មានភាពស៊ីសង្វាក់គ្នាដែលកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដ មែន។

៦-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន។

៧-អំពើរបស់ជនជាប់ចោទបានស្តែងឡើងដោយ មានចេតនាច្របាច់កលើជនរងគ្រោះ បណ្ដាលឲ្យជនរង គ្រោះស្លាប់ ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

៨-ជនជាប់ចោទជានីតិជន ហើយបានប្រព្រឹត្តអំពើល្មើសដោយមានចេតនា និងការយល់ដឹងពីអំពើរបស់ ខ្លួន ដូច្នេះជននេះត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះច្បាប់។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វីរៈ ដែលមានសាវតាជាតិដូចខាងលើ ពីបទៈ ឃាតកម្ម ប្រព្រឹត្តនៅភូមិពោធិ៍ក្រោម ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

១០-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទក្នុងកំរិតដាក់ពន្ធនាគារ ១០ឆ្នាំ ដោយពិចារណា ទៅលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោម:

+អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ អាយុជីវិតរបស់ជនរងគ្រោះ សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ។

+សកម្មភាពល្មើសបានបង្កឲ្យមានព្យសនៈកម្មធ្ងន់ធ្ងរ ។

+ជនជាប់ចោទបានឆ្លើយសារភាព ។ មូលហេតុទាំងនេះនាំឲ្យតុលាការ ពិចារណាប្រកាស ទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ។



Scanned with CamScanner

១១-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ក្រោយពីបានសួរដេញដោលនាពេលសវនាការ ជនជាប់ចោទបានឆ្លើយសារភាពនូវការប្រព្រឹត្តរបស់ខ្លួន ឃើញថា ការសារភាពនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ។ ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ។ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ១១៣៧ ដកសព/១៩ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។ ស្នើរសុំឲ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់ ។ តុលាការយល់ស្របនឹងសេចក្តីសន្និដ្ឋាននេះ ។

១២-មេធាវីការពារក្តីឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថា នៅថ្ងៃកើតហេតុ ជនជាប់ចោទបានខឹងនឹងជនរងគ្រោះដែលថាសុំលែងលះពីខ្លួន ទើបសម្លាប់លើជនរងគ្រោះ ។ ជនជាប់ចោទបានឆ្លើយសារភាព និងទទួលនូវកំហុសដែលខ្លួនបានប្រព្រឹត្ត ។ ស្នើរសុំឲ្យតុលាការផ្តល់នូវស្ថានសម្រាលទោសដល់ជនជាប់ចោទ ។ គប្បីតុលាការពិចារណា ។

១៣-សំណូមពរចុងក្រោយរបស់ជនជាប់ចោទៈ សុំឲ្យតុលាការបន្ធូបន្ថយទោស។ គប្បីតុលាការពិចារណា ។

**សម្រេច**

១.ផ្តន្ទាទោសលើឈ្មោះ [redacted] វីរៈ ហៅ **ល័ក្ខ** ភេទប្រុស អាយុ ៣០ឆ្នាំ ជាជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] វ៉េង (រ) ម្តាយឈ្មោះ [redacted] សុខន (រ) ប្រពន្ធឈ្មោះ [redacted] ស្រីមុំ មានកូន ០២ នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំថ្ងៃខែឆ្នាំ ១២.០៩.២០១៩)

*ដាក់ពន្ធនាគារកំណត់រយៈពេល ១០(ដប់)ឆ្នាំ* ពីបទៈ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិពោធិ៍ក្រោម ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២.សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីនាពេលសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៩កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅកណ្តាល, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]